


# ការវិនិយោគលើទំពាំងនៅក្នុងប្រទេសកម្ពុជា

អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ទំពាំងគឺជាប្រភេទអាហារចម្បងមួយប្រភេទ។ បច្ចុប្បន្នដោយមានបច្ចេកទេសកែច្នៃអាហារ គេអាចរកទិញទំពាំងពេញមួយឆ្នាំ ដោយសារប្រជាជនដែលមានជីវភាពធូរធារកាន់តែមានចំនួនកើនឡើងនៅក្នុងអាស៊ី។ ឱកាសក្នុងផ្គត់ផ្គង់តម្រូវការនេះគឺមានខ្ពស់ខ្លាំងណា ស់នៅក្នុងប្រទេសដែលឫស្សីដុះបានល្អ។ ការបង្កើតនូវប្រតិបត្តិការកែច្នៃទំពាំងត្រូវការផ្ទៃដីដាំដុះឫស្សីសមស្រប និងដៃគូដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ទំពាំងស្រស់ ដឹងពីកម្រិតការកែច្នៃបន្លែទូទៅ ដែលមានរួចមកហើយនៅក្នុងប្រទេសកម្ពុជា និង ការវិនិយោគជាទឹកប្រាក់ចាប់ពី ៣៥,០០០ ដុល្លារអាមេរិកឡើងទៅ។

## ផលិតផលនិងទីផ្សារ



ទំពាំងក្រៀម

ទំពាំងគឺជាពន្លកទំពាំងខ្ចីដែលផ្តល់នូវប្រភពអាហារជាបន្លែដ៏សម្បូរបែបដែលសម្បូរទៅដោយវីតាមីននិងសារធាតុរ៉ែ។ ដោយសារមានការរីកចម្រើននៅក្នុងបច្ចេកវិទ្យាទំពាំងកែច្នៃឬទំពាំងក្រៀមគឺគេអាចរកទិញបាននិងមានការពេញនិយមពេញមួយឆ្នាំ។តម្រូវការប្រើប្រាស់ទំពាំងជាលក្ខណៈប្រពៃណីខ្ពស់បំផុតគឺក្នុងអំឡុងពេលសែនព្រះខែ (ភាគច្រើនទំពាំងក្រៀម) ចំណែកឯទំពាំងស្រស់ត្រូវបានប្រើ- ប្រាស់នៅអំឡុងពេលនៃរដូវប្រមូលផល ទំពាំង។ ទំពាំងកែច្នៃទោះជាក្នុងលក្ខណៈ

| ប្រទេស | ការប្រើប្រាស់ (តោន/ឆ្នាំ) | ចំនួនប្រជាជន (លាននាក់) | ការប្រើប្រាស់របស់មនុស្សម្នាក់ |
|---|---|---|---|
| វៀតណាម | 72,000 | 85 | 0.849 |
| ចិន | 2,400,000 | 1,322 | 1.815 |
| ជប៉ុន | 140,000 | 127 | 1.102 |
| តៃវ៉ាន់ | 233,000 | 23 | 10.130 |
| បាងកក (ប្រទេសថៃ) | 10,000 | 9 | 1.111 |
| តំបន់NEH (ប្រទេសឥណ្ឌា) | 5,685 | 8.68 | 0.655 |
| ភីលីពីន | 72,800 | 91 | 0.800 |

ទីផ្សារនាំមុខរបស់ទំពាំង






ទំពាំងស្រុះនិងច្រកកំប៉ុង






ទំពាំងត្រាំនិងប្រឡាក់គ្រឿង


**Contact information:**
ww.aha-kh.com/bamboo
bamboo@aha-kh.com
+855 89 595 668 (English)
+855 12 550 635 (Khmer)

# វិនិយោគលើមាសបៃតង



## ឫស្សី:សម្ភារៈសំរាប់អនាគត

ជាកំប៉ុងត្រាំ ប្រលាក់គ្រឿង និង សម្ងួតបានផ្តល់ឲ្យអ្នកទីក្រុង និងអ្នកមាន ទ្រព្យសម្បត្តិ អាចទិញនិងទទួលទាន ទំពាំងគ្រប់ពេលវេលាក្នុងមួយឆ្នាំៗ។

ទីផ្សារទំពាំងសំខាន់ទីមួយគឺនៅក្នុងអាស៊ី ខណៈដែលតម្រូវការទីផ្សារអន្តរជាតិ កំពុងមានការកើនឡើងដែលពាណិជ្ជកម្មពិភពលោកត្រូវបានគេប៉ាន់ស្មានថា មានចំនួនប្រហែល ១,៥ ពាន់លានដុល្លារអាមេរិក សូមកត់សម្គាល់ថា ការប្រើប្រាស់ក្នុងស្រុក មិនបានដាក់បញ្ចូលនៅក្នុងទិន្នន័យពាណិជ្ជកម្មនោះទេ។ តម្រូវការក្នុងប្រទេសកម្ពុជាត្រូវបានប៉ាន់ស្មានថា មានចំនួន ១លានដុល្លារអាមេរិក[១] ដោយប្រើប្រាស់ផលិតផលបែបប្រពៃណី។ កាឡានុវត្តភាពសម្រាប់ផលិតផលកែច្នៃមានការកើនឡើងជាមួយនឹងការកើនឡើងនូវកំលាំងនៃការចំណាយរបស់ប្រជាជនកម្ពុជាថ្នាក់មធ្យម។ ផលិតកម្មពីប្រទេសកម្ពុជាអាចប្រកួតប្រជែងបានដោយសារថ្លៃវត្ថុធាតុដើមអាចមានតម្លៃទាបជាងខ្លាំងធៀបនឹងអ្នកប្រកួតនៅក្នុងតំបន់។

## បច្ចេកទេសកែច្នៃ

- ទំពាំងស្រស់ →
- ជំហានទី១: ការបកសំបកនិងការពិនិ →
- ជំហានទី២: ពិនិត្យ/ការចែកថ្នាក់និងការកាត់ →
- ជំហានទី៣:ការចម្អិនទុក →
- ជំហានទី៤: ការលាងសម្អាត →
- ជំហានទី៥: ការចែកថ្នាក់ម្តងទៀត/ការកាត់

ខ្សែសង្វាក់ផលិតកម្មទំពាំងស្រុះ



ម៉ាស៊ីច្រកកំប៉ុង



ម៉ាស៊ីនឈូស



ម៉ាស៊ីនបកសំបក

សង្វាក់ផលិតកម្មអាចត្រូវបានបង្កើតឡើងសម្រាប់ផលិតផលទំពាំងស្រុះឬទំពាំងក្រៀម។ ឧបករណ៍និងម៉ាស៊ីន គឺស្រដៀងគ្នានឹងឧបរកណ៍និង ម៉ាស៊ីនសម្រាប់ការកែច្នៃអាហារដែរ។យើងត្រូវការកន្លែងធម្មតានិងមានការផ្គត់ផ្គង់អគ្គិសនីតែប៉ុណ្ណោះ។ សង្វាក់ឧបករណ៍ពីប្រទេសចិន អាចរកទិញបានក្នុងតម្លៃ ២៥,០០០ ដុល្លារអាមេរិក សម្រាប់ខ្សែសង្វាក់ផលិតកម្មដែលអាចផលិតនិងវេចខ្ចប់ផលិតផលសេះនិងសមតដ៏ច្រើន។

[1]OHK-IFC-MPDF 2006.

**Contact information:**
ww.aha-kh.com/bamboo
bamboo@aha-kh.com
+855 89 595 668 (English)
+855 12 550 635 (Khmer)

# វិនិយោគលើមាសបៃតង



## ឫស្សីៈសម្ភារៈសំរាប់អនាគត

## វត្ថុធាតុដើម



ការដាំទំពាំង

នាពេលបច្ចុប្បន្នធនធានទំពាំងនៅមានកម្រិតនៅឡើយ។ទំពាំងស្រស់ និង ពាក់កណ្តាលការកែច្នៃដែលប្រើប្រាស់ នូវវិធីសាស្ត្របែបប្រពៃណីត្រូវបាន ប្រើប្រាស់លើប្រភេទពូជឫស្សីក្នុងស្រុកមួយចំនួន។ចំការដាំដុះថ្មីត្រូវបានគេ ផ្តល់អានុសាសន៍ថាគួរត្រូវបានអភិវឌ្ឍន៍ជាមួយនឹងពូជដែលផ្តល់ភាពប្រសើរ បំផុតសម្រាប់ទីផ្សារគោលដៅ។ ការអភិវឌ្ឍន៍នេះអាចត្រូវបានធ្វើឡើងដោយ សហការណ៍ជាមួយនឹង អាជ្ញាធរក្នុងស្រុកនិងកសិករ។ ផលិតកម្មដែលទើប នឹងចាប់ផ្តើមដែលមិនទាន់មានលក្ខណៈជាក់ លាក់ដោយប្រើប្រាស់នូវផលិត កម្មដែលបានស្នើខាងលើអាចកែច្នៃប្រហែល១០០០តោនក្នុងមួយឆ្នាំនិង ចំនួននេះនឹងត្រូវការផ្ទៃដី ដាំដុះដែលបានអភិវឌ្ឍពី៤០-៦០ហិចតា។ការដាំដុះថ្មី នឹង ចាប់ផ្តើម ផលិតកម្មទំពាំងពេញលក្ខណៈក្នុងរយៈពេល៣ឆ្នាំ ដោយមានទិន្នផលទំពាំង ដល់ទៅ៤០តោន ក្នុងមួយហិចតាក្នុងមួយឆ្នាំ។

## ហិរញ្ញវត្ថុ

ការចំណាយលើធាតុចូលមានប្រហែល៥០%នៃថ្លៃដំណើរការការចំណាយផ្សេងទៀតស្ថានភាព នៅកម្ពុជា គឺការគ្រប់គ្រង (៣៣%) កំលាំងពលកម្មរោងចក្រ(១២%) ការរំលោះ(៤%) និងផ្សេងៗ ចំនួន(១%)។ តម្លៃលក់ដុំសម្រាប់លិតផល ដែលមាន គុណភាព នៅក្នុងតំបន់គឺ០.៨ ដុល្លារ អាមេរិក/១គីឡូ(ស្រុះ) និង៤ដុល្លារ អាមេរិក/១គីឡូ(ស្ងួត)។ ដោយអាចផលិត បាន៣តោន ក្នុងមួយថ្ងៃរោងចក្រអាចកែច្នៃពី ១៨០-២២០ថ្ងៃ ដោយយោងតាម ប្រភេទដោយផ្តល់ប្រាក់ចំណូល ប្រហែល ២០០,០០០ដុល្លារអាមេរិក/ក្នុងមួយឆ្នាំ។

| វត្ថុធាតុដើម | ទំពាំស្រុះ | ទំពាំងស្ងួត |
|---|---|---|
| ទំពាំងស្រស់និង/ឬចម្អិនទុក/បកសំបក | 2.00kg | 10.00kg |
| | $0.24 | $1.00 |
| សារធាតុបន្ថែម | $0.060 | $0.120 |
| ថាមពល | $0.024 | $0.100 |
| ទឹក | $0.002 | $0.001 |
| ការវេចខ្ចប់ | $0.012 | $0.050 |
| ***ការចំណាយសរុបលើធាតុចូល*** | ***$0.34*** | ***$1.27*** |

**ថ្លៃធាតុចូលសម្រាប់ទិន្នផល១គីឡូក្រាម**

*លក្ខខ័ណ្ឌជាក់ស្តែងអាចបញ្ជាក់ទៅតាមគម្រោងនីមួយៗ។វត្ថុ-ធាតុដើម(១០ ទៅ ១២ សេនក្នុងមួយគីឡូ)រក្សាដដែលដោយប្រៀបធៀបខ្នាតរង្វាស់តាមប្រភេទពូជទំពាំង(ឧទាហរណ៍ នៅចិន ២០សេនក្នុងមួយគីឡូវៀតណាម ១៧សេនក្នុងមួយគីឡូ).*

**Contact information:**
ww.aha-kh.com/bamboo
bamboo@aha-kh.com
+855 89 595 668 (English)
+855 12 550 635 (Khmer)